## សេចក្តីថ្លែងការណ៍រួម៖

# អង្គការផ្នែកសារព័ត៌មានអំពាវនាវឱ្យអាជ្ញាធរបង្កើនការប្រយុទ្ធប្រឆាំងនិទណ្ឌភាពលើឧក្រិដ្ឋកម្មប្រឆាំងអ្នកសារព័ត៌មាន

*ភ្នំពេញ ថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ ២០២០ — នៅក្នុងទិវាអន្តរជាតិបញ្ចប់និទណ្ឌភាពលើឧក្រិដ្ឋកម្មប្រឆាំងអ្នកសារព័ត៌មាននេះ យើងខ្ញុំជាអង្គការធ្វើការងារលើកស្ទួយវិស័យសារព័ត៌មានដែលរួមមានសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា) មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM) ក្លឹបអ្នកសារព័ត៌មានបរទេសនៃកម្ពុជា (OPCC) និងសហព័ន្ធអ្នកសារព័ត៌មានអន្តរជាតិ (IFJ) សម្តែងនូវការព្រួយបារម្ភយ៉ាងខ្លាំងចំពោះនិទណ្ឌភាពដែលបន្តកើតមាន ហើយកំពុងតែបណ្តោយឱ្យអ្នកប្រព្រឹត្តបទល្មើសទៅលើអ្នកសារព័ត៌មាននៅក្នុងប្រទេសកម្ពុជា កម្រត្រូវបាននាំខ្លួនយកមកផ្តន្ទាទោស។ យើងខ្ញុំសូមទទូចឱ្យអាជ្ញាធរចាត់វិធានការជាបន្ទាន់ដើម្បីធានាឱ្យមានការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាព ឯករាជភាព និងតម្លាភាពទៅលើគ្រប់ករណីបទល្មើសទាំងអស់ ដែលជនរងគ្រោះ និងសាច់ញាតិរបស់ពួកគេនៅកំពុងរង់ចាំយុត្តិធម៌នៅឡើយ។*

*ចាប់តាំងពីឆ្នាំ ១៩៩៤មក យ៉ាងតិចណាស់មានអ្នកសារព័ត៌មានចំនួន ១៥នាក់ ត្រូវបានសម្លាប់នៅកម្ពុជា។ ករណីស្ទើរតែទាំងអស់ ជនរងគ្រោះត្រូវបានសម្លាប់ដោយសារតែការងាររបស់ពួកគេ។ ជាក់ស្តែងការស្លាប់របស់ជនរងគ្រោះចំនួន១២នាក់ក្នុងចំណោម ១៥នាក់ខាងលើគឺកើតឡើងក្នុងខណៈពួកគេធ្វើសកម្មភាពរាយការណ៍ព័ត៌មានអំពីទង្វើខុសច្បាប់របស់បុគ្គលមានអំណាចនៅកម្ពុជា។ ក្នុងចំណោមករណីទាំង១៥ មាន១២ករណី ដែលពុំមានជនណាម្នាក់ត្រូវបានកាត់ទោសពីបទឃាតកម្មលើអ្នកសារព័ត៌មានទាំងអស់នោះទេ។*

*ឧក្រិដ្ឋកម្មប្រឆាំងអ្នកសារព័ត៌មាននិងការធ្វើទុក្ខបុកម្នេញលើអ្នកសារព័ត៌មានហាក់នៅតែកើតឡើងជាបន្តបន្ទាប់ ជាពិសេសនៅក្នុងរយៈពេលចុងក្រោយនេះ។ ក្នុងរយៈពេល១០ខែចុងក្រោយនេះ (ចាប់ពីខែមករា ដល់ខែតុលា ឆ្នាំ២០២០) ខេមបូចារកឃើញថា មានអ្នកសារព័ត៌មានសរុប៥៩នាក់បានទទួលរងនូវការធ្វើទុក្ខបុកម្នេញក្នុងរូបភាពផ្សេងៗរួមមាន ការប្រើអំពើហិង្សា*

ការចាប់ខ្លួន ការបាត់បង់ជីវិត និងការរងបណ្តឹងពីតុលាការ។ ក្នុងនោះ មានអ្នកសារព័ត៌មានចំនួន ២៧នាក់ត្រូវបានចាប់ខ្លួន ៧នាក់ជាជនរងគ្រោះនៃការប្រើអំពើហិង្សា និង ម្នាក់បានស្លាប់។

ឧក្រិដ្ឋកម្មប្រឆាំងអ្នកសារព័ត៌មាននាំមកនូវការគំរាមកំហែងយ៉ាងពិតប្រាកដ។ អ្នកសារព័ត៌មានទទួលខុសត្រូវក្នុងការរាយការណ៍ហេតុការណ៍ដែលបានកើតឡើង សរសេរបទវិភាគ និងអត្ថបទអត្ថាធិប្បាយ ដើម្បីគាំទ្រឱ្យមានការបញ្ចេញមតិ និងជជែកពិភាក្សាយ៉ាងរស់រវើក។ អ្នកសារព័ត៌មានឯករាជ្យដើរតួយ៉ាងសំខាន់ក្នុងការទាមទារឱ្យអ្នកមានអំណាចមានទំនួលខុសត្រូវ និងរួមចំណែកយ៉ាងសំខាន់ដើម្បីឱ្យសង្គមមានយុត្តិធម៌។ នៅពេលដែលអ្នកសារព័ត៌មានក្លាយជាមុខសញ្ញានៃអំពើហិង្សាដោយសារតែអ្វីដែលពួកគេបានសរសេរ ឬបានរាយការណ៍ នោះសេរីភាពបញ្ចេញមតិត្រូវបានរារាំងហើយជំនួសដោយការរឹតត្បិតសេរីភាពខ្លួនឯងនិងភាពភ័យខ្លាច។ សាធារណជននឹងពុំមានព័ត៌មាន ហើយអ្នកមានអំណាចនឹងមិនត្រូវបានដាក់ឱ្យទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួននោះទេ។ នៅពេលនគរបាលយុត្តិធម៌ និងតុលាការខកខានក្នុងការស៊ើបអង្កេត និងដាក់ទណ្ឌកម្មចំពោះអំពើហិង្សាលើអ្នកសារព័ត៌មាន នេះជាសារបង្ហាញថាឧក្រិដ្ឋកម្មប្រឆាំងអ្នកសារព័ត៌មានគឺត្រូវបានអនុញ្ញាត។

យើងខ្ញុំជាអង្គការធ្វើការក្នុងវិស័យសារព័ត៌មានដែលមានឈ្មោះដូចបានរៀបរាប់ខាងលើ សូមថ្កោលទោសចំពោះអំពើនិទណ្ឌភាពលើឧក្រិដ្ឋកម្មប្រឆាំងអ្នកសារព័ត៌មាន ដែលធ្វើឱ្យប៉ះពាល់ដល់ពលរដ្ឋ និងសង្គមកម្ពុជាទាំងមូល។ យើងខ្ញុំសូមអំពាវនាវដល់អាជ្ញាធរឱ្យផ្តន្ទាទោសជនល្មើសនៃឧក្រិដ្ឋកម្មប្រព្រឹត្តមកលើអ្នកសារព័ត៌មាន និងសូមឱ្យរាជរដ្ឋាភិបាល ធានាសុវត្ថិភាព និងសន្តិសុខ ជូនដល់អ្នកសារព័ត៌មានគ្រប់រូប ដើម្បីឱ្យពួកគេអាចអនុវត្តសិទ្ធិសេរីភាព ចូលរួមរាយការណ៍ព័ត៌មាននានាដែលកំពុងកើតមានឡើងនៅក្នុងសង្គមដោយមិនមានភាពភ័យខ្លាច ៕

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖
**សម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា)**
លោក ណុប វី នាយកប្រតិបត្តិ ខេមបូចា
ទូរសព្ទ៖ ០១២ ៥១៩ ២៦១
អ៊ីមែល៖ ed@camboja.net

***មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM)***

*លោក អ៊ិត សូធឿត នាយកនៃនាយកដ្ឋានប្រព័ន្ធផ្សព្វផ្សាយ CCIM*

*ទូរសព្ទ៖ ០១២ ៨៩១ ៥៤៥*

*អ៊ីមែល៖ isothoeuth@vodhotnews.com*

***ក្លឹបអ្នកសារព័ត៌មានបរទេសនៃកម្ពុជា (OPCC)***

*Ate Hoekstra ប្រធាន OPCC*

*ទូរសព្ទ៖ ០១៧ ៨៧៨ ៣៤១*

*អ៊ីមែល៖ ate.hoekstra@gmail.com*

***សហព័ន្ធអ្នកសារព័ត៌អន្តរជាតិ (IFJ)***

*Jane Worthington, នាយិកា IFJ ទទួលបន្ទុកតំបន់អាស៊ីប៉ាស៊ីហ្វិក*

*ទូរសព្ទ៖ +៦១ ៤៣៩ ០២៦ ០៩៥*

*អ៊ីមែល៖ jane.worthington@ifj-asia.org*